MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣១៣ សហវ.ប្រក.[illegible]


# ប្រកាស
## ស្តីពី
## ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះគម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

**ប្រការ១ .- គោលបំណង**

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះគម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ "គ.ព.គ.ល.គ." ដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ .- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាសជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ "គ.ល.គ." ដែលធ្វើការពង្រីកសកម្មភាពវិនិយោគរបស់ខ្លួន។

**ប្រការ៣ .- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ៖

**១. គ.ព.គ.ល.គ. ដែលត្រូវទទួលបានការលើកទឹកចិត្តនូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល** សំដៅដល់ការពង្រីកនៃ គ.ល.គ. ដែលធ្វើឡើងតាមរូបភាពណាមួយ ដូចខាងក្រោម៖

ក. ការពង្រីកផលិតកម្មដែលមានស្រាប់។

ខ. ការពង្រីកតាមរយៈការធ្វើពិពិធកម្មមុខសញ្ញាផលិតកម្មដែលស្ថិតក្នុងសៃស្រឡាយផលិតផលជាមួយគ្នា។

គ. ការពង្រីកតាមរយៈការបំពាក់បច្ចេកវិទ្យាទំនើបថ្មីដែលលើកកម្ពស់ផលិតភាព ឬការពារបរិស្ថាន។

ឃ. ករណីការពង្រីកសកម្មភាពផ្សេងទៀត ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

**២. ទុនវិនិយោគ** សំដៅដល់តម្លៃវិនិយោគដែលបង្ហាញជារូបិយវត្ថុ ឬរូបិយបណ្ណបរទេស ដោយមិនរួមបញ្ចូលតម្លៃដីធ្លី និងទុនបង្វិល។

**៣. ទុនវិនិយោគសរុប** សំដៅដល់ទុនវិនិយោគនៃ គ.ល.គ. ដែលបានចុះបញ្ជីដំបូង បូកនឹងទុនពង្រីកនៃ គ.ល.គ. ដែលត្រូវទទួលបានការលើកទឹកចិត្ត។

**៤. ទុនវិនិយោគនៃ គ.ល.គ. ដែលបានចុះបញ្ជីដំបូង** សំដៅដល់ទុនវិនិយោគដែលបានអនុវត្តជាក់ស្ដែងមុនបន្ថែមទុនពង្រីក គ.ល.គ. ដោយគិតតាមតម្លៃប្រវត្តិសាស្ត្រនៃតម្លៃទ្រព្យសកម្មដែលបានវិនិយោគ។ ទ្រព្យសកម្មដែលបានវិនិយោគ រួមមាន អគារនិងរចនាសម្ព័ន្ធរបស់អគារ សំណង់ដែលជាសមាសភាគរបស់អគារ កុំព្យូទ័រ ប្រព័ន្ធព័ត៌មានអេឡិចត្រូនិក ឧបករណ៍អេឡិចត្រូនិក បរិក្ខារទុកដាក់ទិន្នន័យ រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារិម និងបរិក្ខារការិយាល័យ រួមបញ្ចូលទាំងទ្រព្យសកម្មរយៈពេលវែងដទៃទៀត។

**៥. ទុនពង្រីក គ.ល.គ.** សំដៅដល់តម្លៃវិនិយោគបន្ថែមលើ គ.ល.គ. ដែលមានស្រាប់ និងត្រូវប្រើប្រាស់សម្រាប់តែការវិនិយោគលើសម្ភារៈសាងសង់ និងសម្ភារៈបរិក្ខារផលិតកម្មថ្មី។

**ប្រការ៤ .- លក្ខខណ្ឌទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលចំពោះ គ.ព.គ.ល.គ.**

១. ចំពោះ គ.ព.គ.ល.គ. ត្រូវទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលទៅតាមសកម្មភាពវិនិយោគនៃគម្រោងដើម ក្នុងរយៈពេលជាក់លាក់ណាមួយ ទៅតាមប្រភេទក្រុមសកម្មភាពវិនិយោគដែលបានចែងក្នុងបញ្ជីសកម្មភាពវិនិយោគនៃឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា៖

ក. ៩ (ប្រាំបួន) ឆ្នាំ សម្រាប់ក្រុម ១

ខ. ៦ (ប្រាំមួយ) ឆ្នាំ សម្រាប់ក្រុម ២

គ. ៣ (បី) ឆ្នាំ សម្រាប់ក្រុម ៣

២. បន្ទាប់ពីទទួលបានការអនុញ្ញាតពង្រីកសកម្មភាព គ.ល.គ. ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬពីអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត អគ្គនាយកដ្ឋានពន្ធដារនឹងចេញលិខិតបញ្ជាក់ស្តីពីការលើកលែងពន្ធលើប្រាក់ចំណូលចំពោះ គ.ព.គ.ល.គ.។

៣. ទុនពង្រីក គ.ល.គ. ដែលត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល គឺជាទុនវិនិយោគបន្ថែមលើ គ.ល.គ. ដែលបានដាក់ចូលជាក់ស្តែងក្នុងឆ្នាំជាប់ពន្ធ និងត្រូវប្រើប្រាស់សម្រាប់តែវិនិយោគលើសម្ភារៈសាងសង់ និងសម្ភារៈបរិក្ខារផលិតកម្មថ្មីប៉ុណ្ណោះ។ ក្នុងករណីទុនពង្រីក គ.ល.គ. ត្រូវបានដាក់ចូល និងបានប្រើប្រាស់ជាដំណាក់កាលតាមឆ្នាំជាប់ពន្ធនីមួយៗ នោះការលើកលែងពន្ធលើប្រាក់ចំណូល ត្រូវផ្អែកតាមកំណើននៃទុនពង្រីក គ.ល.គ. ដែលបានប្រើប្រាស់លើការវិនិយោគលើសម្ភារៈសាងសង់ និងសម្ភារៈបរិក្ខារផលិតកម្មថ្មីជាក់ស្តែងតាមឆ្នាំជាប់ពន្ធនីមួយៗ។

៤. ការលើកលែងពន្ធលើប្រាក់ចំណូលចំពោះ គ.ព.គ.ល.គ. ត្រូវចាប់គិតពីពេលដែលសហគ្រាសទទួលបានចំណូលដំបូងពីសកម្មភាពពង្រីក គ.ល.គ.។

**ប្រការ៥ ._ ការគណនាប្រាក់ចំណូលដែលត្រូវបានលើកលែងពន្ធចំពោះ គ.ព.គ.ល.គ.**

១. ចំណែកនៃប្រាក់ចំណូលដែលត្រូវបានលើកលែងពន្ធចំពោះ គ.ព.គ.ល.គ. ស្មើនឹងប្រាក់ចំណូលជាប់ពន្ធសរុបគុណនឹងអត្រាទុនពង្រីកនៃ គ.ល.គ.។ អត្រាទុនពង្រីកនៃ គ.ល.គ. ស្មើនឹងទុនពង្រីកនៃ គ.ល.គ. ចែកនឹងទុនវិនិយោគសរុប។ ទុនវិនិយោគសរុប ស្មើនឹងទុនវិនិយោគនៃ គ.ល.គ. ដែលបានចុះបញ្ជីដំបូង (ទុនវិនិយោគមុនស្នើសុំពង្រីក) បូកនឹងទុនពង្រីកនៃ គ.ល.គ ដែលត្រូវទទួលបានការលើកទឹកចិត្ត។ រូបមន្តនៃការគណនាមានដូចខាងក្រោម៖

បចល. = បចស. x (ទព. / ទស.)

បចល. = ប្រាក់ចំណូលដែលត្រូវទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូល

បចស. = ប្រាក់ចំណូលជាប់ពន្ធសរុប

ទព. = ទុនពង្រីក គ.ល.គ. ដែលត្រូវទទួលបានការលើកទឹកចិត្ត

ទស. = ទុនវិនិយោគសរុប (ទច. + ទព.)

ទច. = ទុនវិនិយោគនៃ គ.ល.គ. ដែលបានចុះបញ្ជីដំបូង។

២. ករណី គ.ព.គ.ល.គ. ត្រូវអនុវត្តស្ថិតក្នុងរយៈពេលលើកទឹកចិត្តឱ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមពេលធៀបទៅនឹងប្រាក់ពន្ធត្រូវបង់សរុប សហគ្រាសត្រូវគណនានូវប្រាក់ចំណូលលើកលែងពន្ធតាមលំដាប់លំដោយ ដូចខាងក្រោម៖

ក. គណនាចំណែកនៃប្រាក់ចំណូលដែលត្រូវបានលើកលែងពន្ធចំពោះ គ.ព.គ.ល.គ. ដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ។

ខ. គណនាប្រាក់ចំណូលលើកលែងពន្ធ តាមអត្រាកំណើនតាមពេល ដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌទី១ នៃមាត្រា១៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដោយត្រូវយកចំណូលជាប់ពន្ធសរុប ដកចេញនូវចំណែកនៃប្រាក់ចំណូលដែលត្រូវបានលើកលែងពន្ធចំពោះ គ.ព.គ.ល.គ. គុណនឹងអត្រាលើកលែងតាមឆ្នាំជាប់ពន្ធនីមួយៗ។

**ឧទាហរណ៍ទី១៖ ករណីសហគ្រាសដាក់ទុនពង្រីកស្មើ ១០០%**

សហគ្រាស **កខគ** ជា គ.ល.គ. មានទុនវិនិយោគចុះបញ្ជីដំបូង (ទុនវិនិយោគមុនស្នើសុំពង្រីក) សរុបចំនួន ២២ ០០០ លានរៀល។ នៅដើមឆ្នាំ២០២២ សហគ្រាស **កខគ** បានស្នើសុំពង្រីកសកម្មភាពវិនិយោគរបស់ខ្លួនលើផលិតកម្មដែលមានស្រាប់ ដែលទទួលការអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានទុនវិនិយោគពង្រីកចំនួន ២០ ០០០ លានរៀល និងត្រូវទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ៣ឆ្នាំ។ សហគ្រាសបានប្រើប្រាស់ទុនពង្រីក គ.ល.គ. ស្មើនឹង ១០០% ក្នុងការិយបរិច្ឆេទឆ្នាំជាប់ពន្ធ២០២២ និងទទួលបានប្រាក់ចំណូលជាប់ពន្ធសរុបពី គ.ល.គ. និង គ.ព.គ.ល.គ. ចំនួន ៨ ០០០ លានរៀល។

ការគណនាចំណែកនៃប្រាក់ចំណូលដែលត្រូវទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២២ របស់សហគ្រាស កខគ ដូចខាងក្រោម៖

**ទស.** = **ទប. + ទព.**
= ២២ ០០០ លានរៀល + ២០ ០០០ លានរៀល
= ៤២ ០០០ លានរៀល

**អត្រា ទព.** = **(ទព. / ទស.)**
= (២០ ០០០ លានរៀល / ៤២ ០០០ លានរៀល)
= ៤៨%

**បចល.** = **បចស. x អត្រា ទព.**
= ៨ ០០០ លានរៀល x ៤៨%
= **៣ ៨៤០ លានរៀល**

ចំណែកនៃប្រាក់ចំណូលដែលត្រូវទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលចំពោះ គ.ព.គ.ល.គ. សម្រាប់ឆ្នាំជាប់ពន្ធ២០២២ ស្មើនឹង **៣ ៨៤០ លានរៀល**។ ដោយហេតុថា សហគ្រាសបានប្រើប្រាស់ទុនពង្រីក ស្មើ ១០០% ក្នុងឆ្នាំ២០២២ ដែលជាឆ្នាំលើកទឹកចិត្តដំបូង ដូច្នេះ អត្រាទុនពង្រីកនៃ គ.ល.គ. ត្រូវអនុវត្តតាមអត្រា ៤៨% សម្រាប់ឆ្នាំ២០២៣ និងឆ្នាំ២០២៤ ដូចគ្នានឹងឆ្នាំ២០២២។

**ឧទាហរណ៍ទី២៖ ករណីសហគ្រាសដាក់ទុនពង្រីកជាដំណាក់កាល តាមឆ្នាំជាប់ពន្ធនីមួយៗ**

សហគ្រាស **កខគ** ជា គ.ល.គ. មានទុនវិនិយោគចុះបញ្ជីដំបូង (ទុនវិនិយោគមុនស្នើសុំពង្រីក) សរុបចំនួន ២២ ០០០ លានរៀល។ នៅដើមឆ្នាំ២០២២ សហគ្រាស **កខគ** បានស្នើសុំពង្រីកសកម្មភាពវិនិយោគរបស់ខ្លួនលើផលិតកម្មដែលមានស្រាប់ ដែលទទួលការអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានទុនវិនិយោគពង្រីកចំនួន ២០ ០០០ លានរៀល និងត្រូវទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ៣ឆ្នាំ។ សហគ្រាសបានប្រើប្រាស់ទុនពង្រីក គ.ល.គ. និងទទួលបានប្រាក់ចំណូលជាប់ពន្ធសរុបពី គ.ល.គ. និង គ.ព.គ.ល.គ. តាមឆ្នាំនីមួយៗ ដូចខាងក្រោម៖

**១. នៅក្នុងឆ្នាំ២០២២ (ឆ្នាំទី១)៖** បានប្រើប្រាស់ទុនពង្រីកសរុបចំនួន ៤ ០០០ លានរៀល ស្មើនឹង ២០% និងមានប្រាក់ចំណូលជាប់ពន្ធសរុបប្រចាំឆ្នាំ២០២២ ចំនួន ២ ០០០ លានរៀល។

**២. នៅក្នុងឆ្នាំ២០២៣ (ឆ្នាំទី២)៖** បានប្រើប្រាស់ទុនពង្រីកសរុបចំនួន ១៥ ០០០ លានរៀល ស្មើនឹង ៧៥% និងមានប្រាក់ចំណូលជាប់ពន្ធសរុបប្រចាំឆ្នាំ២០២៣ ចំនួន ៦ ០០០ លានរៀល។

**៣. នៅឆ្នាំ២០២៤ (ឆ្នាំទី៣)៖** បានប្រើប្រាស់ទុនពង្រីកសរុបចំនួន ២០ ០០០ លានរៀល ស្មើនឹង ១០០% និងមានប្រាក់ចំណូលជាប់ពន្ធសរុបប្រចាំឆ្នាំ២០២៤ ចំនួន ៨ ០០០ លានរៀល។

ការគណនាចំណែកនៃប្រាក់ចំណូល ដែលត្រូវទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំទៅតាមឆ្នាំជាប់ពន្ធនីមួយៗ របស់សហគ្រាស កខគ ដូចខាងក្រោម៖

**១.សម្រាប់ឆ្នាំជាប់ពន្ធ២០២២ (ឆ្នាំទី១)**

**ទស.** = **ទប. + ទព.**
= ២២ ០០០ លានរៀល + ៤ ០០០ លានរៀល
= ២៦ ០០០ លានរៀល

**អត្រា ទព.** = **(ទព. / ទស.)**
= (៤ ០០០ លានរៀល / ២៦ ០០០ លានរៀល)
= ១៥%

**បចល.** **= បចស. x អត្រា ទព.**
= ២ ០០០ លានរៀល x ១៥%
= **៣០០ លានរៀល**

ដូច្នេះ ចំណែកនៃប្រាក់ចំណូល ដែលត្រូវទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលចំពោះ គ.ព.គ.ល.គ. សម្រាប់ឆ្នាំជាប់ពន្ធ២០២២ ស្មើនឹង **៣០០ លានរៀល។**

**២.សម្រាប់ឆ្នាំជាប់ពន្ធ២០២៣ (ឆ្នាំទី២)**

**ទស.** **= ទប. + ទព.**
= ២២ ០០០ លានរៀល + ១៥ ០០០ លានរៀល
= ៣៧ ០០០ លានរៀល

**អត្រា ទព.** **= (ទព. / ទស.)**
= (១៥ ០០០ លានរៀល / ៣៧ ០០០ លានរៀល)
= ៤១%

**បចល.** **= បចស. x អត្រា ទព.**
= ៦ ០០០ លានរៀល x ៤១%
= **២ ៤៦០ លានរៀល**

ដូច្នេះ ចំណែកនៃប្រាក់ចំណូល ដែលត្រូវទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលចំពោះ គ.ព.គ.ល.គ. សម្រាប់ឆ្នាំជាប់ពន្ធ២០២៣ ស្មើនឹង **២ ៤៦០ លានរៀល។**

**៣.សម្រាប់ឆ្នាំជាប់ពន្ធ២០២៤ (ឆ្នាំទី៣)**

**ទស.** **= ទប. + ទព.**
= ២២ ០០០ លានរៀល + ២០ ០០០ លានរៀល
= ៤២ ០០០ លានរៀល

**អត្រា ទព.** **= (ទព. / ទស.)**
= (២០ ០០០ លានរៀល / ៤២ ០០០ លានរៀល)
= ៤៨%

**បចល.** **= បចស. x អត្រា ទព.**
= ៨ ០០០ លានរៀល x ៤៨%
= **៣ ៨៤០ លានរៀល**

ដូច្នេះ ចំណែកនៃប្រាក់ចំណូល ដែលត្រូវទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលចំពោះ គ.ព.គ.ល.គ. សម្រាប់ឆ្នាំជាប់ពន្ធ២០២៤ ស្មើនឹង **៣ ៨៤០ លានរៀល។**

### ឧទាហរណ៍ទី៣៖ ករណីសហគ្រាសពង្រីកសកម្មភាពវិនិយោគ ស្ថិតនៅក្នុងរយៈពេលលើកទឹកចិត្តឱ្យបង់ពន្ធលើប្រាក់ចំណូល តាមអត្រាកំណើនតាមពេល

សហគ្រាស កខគ ជា គ.ល.គ. មានទុនវិនិយោគចុះបញ្ជីដំបូង (ទុនវិនិយោគមុនស្នើសុំពង្រីក) សរុបចំនួន ២២ ០០០ លានរៀល។ នៅដើមឆ្នាំ២០២២ សហគ្រាស កខគ បានស្នើសុំពង្រីកសកម្មភាពវិនិយោគរបស់ខ្លួនលើផលិតកម្មដែលមានស្រាប់ ដែលទទួលការអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានទុនវិនិយោគពង្រីកចំនួន ២០ ០០០ លានរៀល និងត្រូវទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលចំនួន ៣ឆ្នាំ។ សហគ្រាសបានប្រើប្រាស់ទុនពង្រីក គ.ល.គ ស្មើនឹង ១០០% ក្នុងការិយបរិច្ឆេទឆ្នាំជាប់ពន្ធ២០២២ និងទទួលបានប្រាក់ចំណូលជាប់ពន្ធសរុបពី គ.ល.គ. និង គ.ព.គ.ល.គ សរុបចំនួន ៨ ០០០ លានរៀល។ ឆ្នាំ២០២២ គឺជាឆ្នាំទី១ ដែលសហគ្រាសទទួលបានការលើកទឹកចិត្តឱ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមពេលធៀបទៅនឹងប្រាក់ពន្ធត្រូវបង់សរុប។

ការគណនាចំណែកនៃប្រាក់ចំណូលដែលត្រូវទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២២ របស់សហគ្រាស កខគ ដូចខាងក្រោម៖

**១. គណនាប្រាក់ចំណូលលើកលែងពន្ធចំពោះ គ.ព.គ.ល.គ.៖**

**ទស.** **= ទប. + ទព.**

= ២២ ០០០ លានរៀល + ២០ ០០០ លានរៀល

= ៤២ ០០០ លានរៀល

**អត្រា ទព.** **= (ទព. / ទស.)**

= (២០ ០០០ លានរៀល / ៤២ ០០០ លានរៀល)

= ៤៨%

**បចល.** **= បចស. x អត្រា ទព.**

= ៨ ០០០ លានរៀល x ៤៨%

= **៣ ៨៤០ លានរៀល**

**២. គណនាប្រាក់ចំណូលលើកលែងពន្ធ តាមអត្រាកំណើនតាមពេល៖**

= ប្រាក់ចំណូលជាប់ពន្ធសរុប - ចំណែកនៃប្រាក់ចំណូលលើកលែងពន្ធចំពោះ គ.ព.គ.ល.គ.

= ៨ ០០០ លានរៀល - ៣ ៨៤០ លានរៀល

= ៤ ១៦០ លានរៀល x ៧៥%

**= ៣ ១២០ លានរៀល**

ដូច្នេះ ចំណែកនៃប្រាក់ចំណូលដែលត្រូវទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូល សម្រាប់ឆ្នាំជាប់ពន្ធ២០២២ ស្មើនឹង **៦ ៩៦០ លានរៀល** (៣ ៨៤០ លានរៀល + ៣ ១២០ លានរៀល)។

**ប្រការ៦ ._ ការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ១% និងពន្ធអប្បបរមា**

១. ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែអត្រា ១% សម្រាប់ គ.ព.គ.ល.គ. ត្រូវបានលើកលែងផ្អែកតាមសមាមាត្រនៃអត្រាទុនពង្រីក គ.ល.គ. ក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូលនៃគម្រោងពង្រីក។

២. គ.ព.គ.ល.គ. ទទួលបានការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។

**ប្រការ៧ ._ ការដកហូតការលើកទឹកចិត្ត**

អគ្គនាយកដ្ឋានពន្ធដារ នឹងជូនដំណឹងមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត ដើម្បីមានវិធានការតាមនីតិវិធីជាធរមាន ក្នុងការដកហូតការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះ គ.ព.គ.ល.គ. ក្នុងករណីណាមួយដូចខាងក្រោម៖

១. សហគ្រាសមិនបានប្រើប្រាស់ទុនពង្រីក គ.ល.គ. សម្រាប់វិនិយោគលើសម្ភារៈសាងសង់ និងសម្ភារៈបរិក្ខារផលិតកម្មថ្មី ដែលបានស្នើសុំពង្រីកសកម្មភាពវិនិយោគរបស់ខ្លួន។

២. សហគ្រាសមិនបានដាក់ទុនពង្រីក គ.ល.គ. គ្រប់ចំនួនតាមការអនុញ្ញាត មុនផុតរយៈពេលលើកលែងពន្ធចំពោះ គ.ព.គ.ល.គ.។

៣. សហគ្រាសមិនបានបំពេញកាតព្វកិច្ចសារពើពន្ធត្រឹមត្រូវ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។

**ប្រការ៨ ._ និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ ._ ការអនុវត្ត**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦កើត ខែទុតិយាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ